គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - BCV - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CJR- CSD - CWCC - GENEROUS
HROTP – IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC – PDP - PJJ - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

គណៈកម្មាធិការប្រព្រឹត្តិកម្ម សំដែងការព្រួយបារម្ភអំពីជម្លោះដែលកំពុងកើតមានឡើងរវាង សហចៅក្រមស៊ើបអង្កេតនៅ អ.វ.ត.ក

ភ្នំពេញ, ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១១

ជម្លោះដែលកំពុងកើតមានថ្មីៗរវាងសហចៅក្រមស៊ើបអង្កេត នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានគេមើលឃើញជាបញ្ហាព្រួយបារម្ភដ៏ធំមួយ ហើយគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) សូមជំរុញឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការជាមួយគ្នាប្រកបដោយភាពចុះសម្រុងខាងវិជ្ជាជីវៈប្រកាន់ខ្ជាប់នូវការគោរពដល់ឯករាជ្យភាពតុលាការ និងនីតិរដ្ឋ។ នេះគឺជាបញ្ហាសំខាន់ណាស់ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីកាន់តែចាស់ៗ ហើយនឿយណាយនឹងការពន្យាពេលជារឿយៗទាក់ទងនឹងសំណុំរឿង០០៣ និង០០៤ ដែលកំពុងនៅទ្រឹង។ ដើមបណ្តឹងរដ្ឋប្បវេណីរំពឹងថាតុលាការបំពេញតួនាទីរបស់ខ្លួន ដើម្បីឈានដល់ការសម្រេចឯករាជ្យមួយក្នុងពេលវេលាសមហេតុផល។

គណៈកម្មាធិការប្រព្រឹត្តិកម្ម ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលចំនួន២៣ ដែលកំពុងធ្វើការក្នុងវិស័យសិទ្ធិមនុស្ស លិទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ជឿថាវាមិនត្រឹមត្រូវទេ ដែលថា ការងាររបស់ចៅក្រមដែលបានស្បថរួចហើយនោះត្រូវបានរាំងស្ទះ។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងច្បាស់លាស់ណាស់ចំពោះបញ្ហានេះ។ យោងតាមមាត្រា២៥ និង២៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិបំរុងបានត្រូវតែងតាំងក្នុងលក្ខណៈជាផ្លូវការរួចទៅហើយ។ យោងតាមមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចៅក្រមអន្តរជាតិបំរុងរូបនេះ ត្រូវជំនួសអតីតសហចៅក្រមស៊ើបអង្កេតដែលបានឈប់ និងត្រូវបានផ្តល់កាតព្វកិច្ចដើម្បីបំពេញតួនាទីរបស់ខ្លួន។

ដូច្នេះ យើងសូមជំរុញឲ្យសហចៅក្រមស៊ើបអង្កេតទាំងពីរធ្វើការជាមួយគ្នាឲ្យបានល្អ និងស្របទៅតាមតួនាទីរបស់ខ្លួនដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ ការពន្យាពេលបន្ថែមទៀតនឹងអាចធ្វើឲ្យខូចយ៉ាងធ្ងន់ធ្ងរដល់ជំនឿទុកចិត្តលើសាលាក្តីកូនកាត់នេះ។ សង្គមស៊ីវិលនឹងបំពេញកាតព្វកិច្ចរបស់ខ្លួនតាមរយៈការបន្តតាមដានសេចក្តីសម្រេច ដែលនឹងកើតមាននៅពេលខាងមុខនេះ និងក៏ទាមទារឲ្យតុលាការបំពេញតួនាទីដោយឯករាជ្យពេញលេញផងដែរ។ ក្នុងន័យនេះ យើងក៏សូមរំលឹកថាសង្គមស៊ីវិលនឹងប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ២០១១ ក្រោមប្រធានបទ "ប្រព័ន្ធតុលាការឯករាជ្យ និងសេរីភាពក្នុងការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃយុត្តិធម៌សង្គម និងការគោរពសិទ្ធិមនុស្ស" ។

<u>សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:</u>

| | | |
|---|---|---|
| លោក ធន សារាយ | ប្រធានសម្របសម្រួល CHRAC<br>និងប្រធាននៃសមាគមអាដហុក | ទូរស័ព្ទ: ០១៦ ៨៨០ ០៨៨ |
| លោក សុក សំអឿន | នាយកប្រតិបត្តិនៃអង្គការ CDP | ទូរស័ព្ទ: ០១២ ៩០១ ១៩៩ |
| លោក ហង្ស ឆាយ៉ា | នាយកប្រតិបត្តិនៃអង្គការ KID | ទូរស័ព្ទ: ០១២ ៨៦៥ ៩១០ |
| លោក រុន សារាយ | នាយកប្រតិបត្តិនៃអង្គការ LAC | ទូរស័ព្ទ: ០១២ ៨៣៨ ៣៨១ |